ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្ដីជូនព័ត៌មាន
# ស្ដីពី
# ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ សម្រាប់ក្រុមអាយុ ៦០ឆ្នាំឡើង ចាប់ពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១

យោងតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នាល្ងាចថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២១ ក្រសួងសុខាភិបាល សូមគោរពជម្រាបជូន និងធ្វើការណែនាំជូនដល់សាធារណជនទាំងអស់ឲ្យបានជ្រាបពីនីតិវិធីនៃការចាក់វ៉ាក់សាំងកូវីដ-១៩នេះ មានដូចខាងក្រោម៖

១. ដោយសង្កេតឃើញថា បងប្អូនប្រជាពលរដ្ឋដែលមានអាយុចាប់ពី ៦០ឆ្នាំឡើង មានបំណងស្ម័គ្រចិត្តចាក់វ៉ាក់សាំងកូវីដ-១៩ ច្រើន ហើយសម្រុកមកចាក់ដោយមានការកកស្ទះ និងរង់ចាំយូរនោះ ក្រសួងសុខាភិបាល សូមធ្វើការផ្អាកការចាក់វ៉ាក់សាំង AstraZeneca ជាបណ្ដោះអាសន្នសិននៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២១ ហើយនឹងចាប់ដំណើរការចាក់ឡើងវិញនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ ដើម្បីទុកពេលវេលាជូនអាជ្ញាធរថ្នាក់ក្រោមជាតិនៅរាជធានីភ្នំពេញ ខេត្តកណ្ដាល និងខេត្តព្រះសីហនុ ធ្វើការសម្របសម្រួលរៀបចំក្រុមប្រជាជនដែលនៅក្នុងក្រុមអាយុនេះ ដើម្បីមកចាក់ទៅតាមថ្ងៃនីមួយៗវិញ។ រីឯ វ៉ាក់សាំងស៊ីណូហ្វាម សម្រាប់ក្រុមអាទិភាពដែលក្រសួងធ្លាប់បានចេញសេចក្ដីជូនព័ត៌មានរួចហើយនោះ នៅតែបន្តចាក់ដដែល ដោយមិនមានការផ្អាកនោះឡើយ។

២. ការចាក់វ៉ាក់សាំងកូវីដ-១៩ គឺដោយឈរលើ **គោលការណ៍ស្ម័គ្រចិត្ត និងមិនគិតថ្លៃ**។

៣. វ៉ាក់សាំងដែលផលិតនៅប្រទេសឥណ្ឌាដោយមានអាជ្ញាប័ណ្ណពី AstraZeneca "**កូវីសែល** (COVISHIELD)" ចាក់លើកទី១ (ដូសទី១) រួចហើយ សូមអញ្ជើញមកទទួលការចាក់វ៉ាក់សាំងដដែលនេះជាលើកទី២ (ដូសទី២) ក្នុងរយៈពេលពី ៤ ទៅ ៨សប្ដាហ៍ បន្ទាប់ពីថ្ងៃចាក់លើកទី១ កុំបីអាក់ខានឡើយ ហើយនឹងចាក់ជូនចាប់ពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ ជូនដល់ប្រជាពលរដ្ឋ ដែលមានអាយុចាប់ពី ៦០ឆ្នាំឡើងទៅ ដែលរៀបចំដោយអាជ្ញាធរមូលដ្ឋាន។

៤. ការចាក់វ៉ាក់សាំង នឹងប្រព្រឹត្តទៅ ដូចខាងក្រោមនេះ៖

៤.១. ចំពោះការចាក់វ៉ាក់សាំង AstraZeneca បន្តឡើងវិញនេះ អាជ្ញាធរមូលដ្ឋាន (ភូមិ/ឃុំ-សង្កាត់) នៃរាជធានី-ខេត្ត នឹងចុះស្រង់ស្ថិតិ រួចផ្ដល់លិខិតអញ្ជើញដល់បងប្អូនប្រជាពលរដ្ឋ ឲ្យទៅទទួលវ៉ាក់សាំងរៀងរាល់ម៉ោងធ្វើការ នៅតាមមន្ទីរពេទ្យបង្អែករាជធានី-ខេត្ត និងមន្ទីរពេទ្យបង្អែកស្រុកប្រតិបត្តិ ដែលស្ថិតនៅក្នុងមូលដ្ឋានរបស់បងប្អូនប្រជាពលរដ្ឋកំពុងរស់នៅ៖

- ចំពោះយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ (AstraZeneca /Serum Institute of India "COVISHIELDTM") នឹងត្រូវផ្ដល់ជូនក្រុមមនុស្សដែលងាយរងគ្រោះនឹងជំងឺកូវីដ-១៩ ដែលមានអាយុចាប់ពី ៦០ឆ្នាំឡើងទៅ ក្នុងមូលដ្ឋានរាជធានីភ្នំពេញ ខេត្តកណ្ដាល និងខេត្តព្រះសីហនុ តែប៉ុណ្ណោះ។ ដើម្បីទទួលបានការចាក់វ៉ាក់សាំងកូវីដ-១៩ បងប្អូនប្រជាពលរដ្ឋ ត្រូវភ្ជាប់មកជាមួយនូវលិខិតអញ្ជើញដែលទទួលបានពីអាជ្ញាធរមូលដ្ឋាន ព្រមទាំងត្រូវបង្ហាញឯកសារសម្គាល់អត្តសញ្ញាណ ដូចជា អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ សៀវភៅគ្រួសារ សំបុត្រអត្រានុកូលដ្ឋាន និងលិខិតឆ្លងដែន ជាដើម ដើម្បីផ្ទៀងផ្ទាត់។
- ចំពោះវ៉ាក់សាំងស៊ីណូហ្វាម "Sinopharm Beijing Institute of Biological Products" ដែលជាជំនួយរបស់សាធារណរដ្ឋប្រជាមានិតចិន នឹងត្រូវផ្ដល់ជូនប្រជាពលរដ្ឋដែលមានអាយុចាប់ពី ១៨ ដល់ ៥៩ឆ្នាំ ហើយត្រូវបានកំណត់ផ្ដល់ជូនក្រុមមនុស្សអាទិភាព ដែលក្រសួងធ្លាប់បានចេញសេចក្ដីជូនព័ត៌មានពីមុនរួចមក ដូចជា បុគ្គលិកសុខាភិបាល កងកម្លាំងនគរបាលជាតិ ចំណុះស្នងការដ្ឋានរាជធានី-ខេត្ត មន្ត្រីរាជការស៊ីវិលជួរមុខ និងមន្ត្រីមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា អាជ្ញាធរមូលដ្ឋាន កម្មករ-កម្មការិនីប្រមូលសំរាម។ល។ ដើម្បីទទួលបានការចាក់វ៉ាក់សាំងកូវីដ-១៩ ក្រុមមនុស្សអាទិភាពខាងលើ ត្រូវភ្ជាប់មកជាមួយនូវលិខិតអញ្ជើញដែលទទួលបានពីអាជ្ញាធរមូលដ្ឋាន ឬ ក្រសួង-ស្ថាប័នសាមី ព្រមទាំងត្រូវបង្ហាញឯកសារសម្គាល់